# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៧. អនក្រ .បក

## អនុក្រឹត្យ

### ស្តីពី

### ការធ្វើអនុបយោគ

### ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ៣៨អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្ម

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សម្រេច

មាត្រា ១.-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ រួមមានៈ

-ទីតាំងការិយាល័យគ្រឿងយន្តកសិកម្ម ស្ថិតនៅភូមិកសិកម្ម ឃុំស្រង៉ែ ខេត្តសៀមរាប ដែលមានទំហំដី ១៥.៤០០ ម៉ែត្រក្រឡា។

-ទីតាំងអគារចាស់ៗ ចំនួន០៤កន្លែង របស់មន្ទីរពត៌មាន ខេត្តក្រចេះ រួមមានៈ

.អគារទំហំ ១៤០ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវសុរាម្រិត ភូមិវត្ត សង្កាត់ក្រចេះ ក្រុងក្រចេះ។

.អគារទំហំ ៣៩ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវសុរាម្រិត ភូមិវត្ត សង្កាត់ក្រចេះ ក្រុងក្រចេះ។

.អគារទំហំ ៣៣ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវលេខ៨ ភូមិវត្ត សង្កាត់ក្រចេះ ក្រុងក្រចេះ។

.អគារទំហំ ៦៦ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវលេខ៨ ភូមិវត្ត សង្កាត់ក្រចេះ ក្រុងក្រចេះ។

-ទីតាំងសាលាឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង មានទំហំដី ៣.០០៩ ម៉ែត្រក្រឡា។

-ប៉ុស្តិ៍នគរបាល រដ្ឋបាល សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលមានទំហំអគារ ៤៨ ម៉ែត្រក្រឡា។

-ទីតាំងការិយាល័យរដ្ឋបាលព្រៃឈើ និងការិយាល័យជលផល រាជធានីភ្នំពេញ ស្ថិតនៅកែងផ្លូវលេខ៦៣ និងផ្លូវលេខ ១០២ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលមានទំហំដី ៥៩០ម៉ែត្រក្រឡា។

-ទីតាំងអតីតរោងពុម្ពនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តបាត់ដំបង ស្ថិតនៅផ្លូវលេខ១ ភូមិ២០ ឧសភា សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ដែលមានទំហំដី ២១៤ ម៉ែត្រក្រឡា។

-ទីតាំងការិយាល័យចំណុះ និងទីតាំងមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ រួមមានៈ

.ដីការិយាល័យគ្រឿងយន្តកសិកម្ម ស្ថិតនៅភូមិគោកស្វាយ ឃុំឫស្សីក្រោក ស្រុកមង្គលបុរី ដែលមានទំហំ ១.៤៥៤ ម៉ែត្រក្រឡា។

.ដីការិយាល័យរុក្ខាប្រមាញ់ ការិយាល័យជលផល និងដីទំនេររបស់មន្ទីរកសិកម្ម ស្ថិតនៅផ្លូវលេខ ៦៩ ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ដែលមានទំហំ ៧.៨៧២ ម៉ែត្រក្រឡា។

.ដីស្ថានីយ៍កសិកម្មស្ពានក្រឡ ស្ថិតនៅភូមិបន្ទាយនាង ឃុំបន្ទាយនាង ស្រុកមង្គលបូរី ដែលមានទំហំ ២៣៧.៣០៦ ម៉ែត្រក្រឡា។

.មន្ទីរកសិកម្ម ស្ថិតនៅក្នុងប្លុកអគារអក្សរអ៊ុយ ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ដែលមានទំហំដីសរុប ៦៤០ម៉ែត្រក្រឡា។

-ទីតាំងអគ្គនាយកដ្ឋានពត៌មាន និងសោតទស្សន៍ នៃក្រសួងពត៌មាន ស្ថិតនៅសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលមានទំហំដី ១.៦២០ ម៉ែត្រក្រឡា។

**មាត្រា ២.-**

ការលុបនិងការកត់ត្រាផ្លូវនៃការដោះដូរទៅក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សាលារាជធានីភ្នំពេញ សាលាខេត្តសៀមរាប សាលាខេត្តព្រៃវែង សាលាខេត្តក្រចេះ សាលាខេត្តបន្ទាយមានជ័យ និង សាលាខេត្តបាត់ដំបង។

**មាត្រា ៣.-**

ការបំពេញបែបបទផ្ទេរកម្មសិទ្ធិរបស់ភាគីឯកជនលើទីតាំងរបស់រដ្ឋត្រូវប្រព្រឹត្តទៅតាមច្បាប់ និងគោលការណ៍កំណត់ជាធរមាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប អភិបាលខេត្តបាត់ដំបង អភិបាលខេត្តបន្ទាយមានជ័យ អភិបាលខេត្តក្រចេះ និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ២០១០

ព្រះរាជាណាចក្រកម្ពុជា
នាយករដ្ឋមន្ត្រី
ទីស្តីការគណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋាន រដ្ឋសភា
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការ រាជរដ្ឋាភិបាល
-ដូចមាត្រា ៥
-ឯកសារ-កាលប្បវត្តិ